Theology on the Web.org.uk

Making Biblical Scholarship Accessible

This document was supplied for free educational purposes. Unless it is in the public domain, it may not be sold for profit or hosted on a webserver without the permission of the copyright holder.

If you find it of help to you and would like to support the ministry of Theology on the Web, please consider using the links below:

Buy me a coffee https://www.buymeacoffee.com/theology

PATREON https://patreon.com/theologyontheweb

PayPal https://paypal.me/robbradshaw

A table of contents for *Honeycomb* can be found here:

https://biblicalstudies.org.uk/articles_honeycomb.php

HONEYCOMB 4/2 (July 2003): 26–33

# God Has Come Close



*Russell H. BOWERS, Jr.*

In the town of Anuradhapura in northern Sri Lanka stands one of the island's most sacred shrines. A Bo tree grows there that is said to be a direct descendant of the one under which the Buddha was enlightened. This old and sacred tree is surrounded by a metal fence, and hundreds of pilgrims come every day to meditate in front of it. During a recent visit I saw scores of people with hands folded in *sampeah* facing that tree, many with eyes closed. I asked my guide, "Are they praying to the Buddha?" "No," she replied. "The Buddha has passed beyond this life into *nirvana*. He cannot hear or answer prayer. These people are rather meditating on the Buddha's sayings and showing their respect. If they have a need and want to pray, they go to a *devada*."

The same kind of thing happens elsewhere in the world and with religions other than Buddhism. Many people intuitively understand that there is a Creator God, who designed and made all we see. The

---

This article was first presented as a Christmas message in Phnom Penh on 20 December 2002.

world is too well designed, and living beings too complex, to simply have emerged by chance or through endlessly-repeated cycles of history. If I see a computer, I know that somewhere there must be a computer designer; a watch requires a watch maker; a moto a moto manufacturer. Likewise, a rice seed that knows how to send its roots down for water and its leaves up for sunlight and air; a bird that soars the winds of heaven; and a human who can think and create; all mean that a wise designer and maker has been at work. We are not accidents, and most people recognize that. But many who know that there is a Creator fear that he is distant, perhaps unconcerned about us, virtually unknown and unknowable. We his creatures have been estranged from him. So if we need help in our daily lives we turn to lesser but closer deities and spirits.

Some of us worry about ghosts or ancestors that may harm us; others sacrifice to a *neak ta*; Thai people sacrifice to spirits called *phi*; in Myanmar coconuts and red cloth are offered to *nats*. Many Muslim people take care not to offend the *jinn*. And the list goes on and on. A common feeling around the world is that the most important and powerful god—the Great God who created us—is too big or distant or offended to care any longer for the people he made, and so we try to find help from lesser sources.

We find this attitude even in the Bible. The young man Daniel belonged to the nation of Israel. He worshiped the true and Great God, but his nation had been defeated in war by its enemy Babylon. So now Daniel was forced to serve the pagan Babylonian king. One night this king dreamed a dream and wanted to know its interpretation. He summoned his wise men and demanded, "Tell me what I dreamed, and then tell me what it means." They answered, "O king, you tell us the dream, and then we will interpret it for you." The king replied, "No, you tell me the dream. Then I will know that you are not just inventing something in your minds, but can tell me the true interpretation." The wise men protested in dismay to the king, "There is not a man on earth who can do what the king asks! No king, however great and mighty, has ever asked such a thing of any magician or enchanter or astrologer. What the king asks is too difficult. No one can reveal it to the king except the gods, *and they do not live among men*." Do we hear

what these wise men said? There are gods who are wise and powerful, and even know such things as what people dream. But they are far away; they do not live among people or speak to us; we have no way of interacting with them. When we are in trouble we have to seek help from lesser (and sometimes false) spirits.

So this is a thread of thought throughout history—a Great God (or gods) exists. But he is too great or too distant. We can't contact him; he can not or will not help.

It can be terrifying to be separated from the wise and powerful who can help us. I have read several accounts of life in Cambodia under the Khmer Rouge, and have just started reading another. In this the author was a nine-year-old girl on that fateful day of April 17, 1975, when Pol Pot's pawns pushed Phnom Penh's people to the provinces. As this girl and her family shuffled with the crowds in their flight from the city, they passed an unattended three-year-old boy screaming and searching for his parents. He was lost and alone in a new, strange, dangerous, and terrifying world. His strong parents who had always comforted and protected him were nowhere to be found.

How like that little boy we sometimes are! We find ourselves alone, having to rely on our own limited (and sometimes faulty) wisdom and resources in a world where we face droughts and famine and wars and corruption and terrorism and AIDS and sick children. We cry out, but no one stops to help. The Great God, if he is there, is distant and silent. So we grasp for anything close by we think might help, like a drowning man who grasps at bubbles or sticks on the surface in a desperate attempt to help him float.

There is some truth in the idea that the Great God is distant. It was not always so, but is now. When God created the first man and woman he used to stoop to walk and talk with them. But one day they rebelled against his command, and so lost their close fellowship with the Almighty. Centuries later God said to his people the nation of Israel, "Surely the arm of Yahweh is not too short to save, nor his ear too dull to hear. But your iniquities have separated you from your God; your sins have hidden his face from you, so that he will not hear." Just as you and I do not wear into our houses sandals in which we have slogged through the sewerage on the streets, but leave them outside, even so

the clean and holy God does not allow wickedness and rebellion in his presence. Our sins have separated us from our God; our sins have hidden his face so that he will not hear. We are three-year-old boys screaming for help unheard in a world gone wild.

If that were the only message the Bible teaches, it would be sad indeed. But this is Christmas. Christmas is the story of how the Great God—the one who made us, knows us, and is wise and powerful enough to help us—has come close. He has indeed been offended by our sins, more than we are by filthy sandals, but in his love he has come near. He has come near to show us who he is, to cleanse us from our sin, and to restore us to the closeness we as a race once enjoyed. The Old Testament of the Bible predicted the coming of a deliverer whose title would be "Immanuel." "Immanuel" is a Hebrew word consisting of three smaller Hebrew words that together mean "God with us." The New Testament of the Bible tells the story of how this Immanuel—this one whose title means "God with us"—has come. But how has he come? In what way, and how close, has the Great God of Creation come to us?

Two weeks ago I attended the Third World Buddhist Conference at the *Veang* and Chaktomuk Theater. High monks and dignitaries from sixteen countries were there. At the opening ceremony our own King Sihanouk gave a speech, and then with the queen stood on the steps of the Silver Pagoda to have his photo taken with the delegates. I saw him—but only from two hundred meters away. The king was surrounded by officials, invited guests, and security guards. Most days I am not near the king at all. The closest I get is to hear about him on the radio or see his picture in the newspaper. I saw the king two years ago on Independence Day, but at the Conference was the first time I had ever heard him speak. So on December 5, 2002, for me the King of Cambodia had come close ... but not very close.

How close has the King of Heaven come? If kings of this earth rarely come near, but usually surround themselves with guards and dignitaries and finery, surely the God of Creation will keep himself at greater distance from us still. But Christmas is the story of how God came very, very close.

The one whose title is Immanuel—God with us—was born as a baby. But he was not born in a palace to a royal family, so that only a privileged few could ever hope to see him. He was born to a poor, traveling couple that found themselves with no place to sleep for the night. They were temporarily homeless; there was no place even for his mother Mary to give birth. So apparently she did so in some kind of feeding room for animals. It may have been a barn of some type, or a cave, or a place outside where animals are fed. But after Jesus was born his mother laid him in an animals' feeding box. If this baby, Jesus, is truly Immanuel, then God has indeed come very close.

The baby's first visitors were not prime ministers or court dignitaries, but shepherds. Shepherds were common figures in Israel in those days. They performed an important role in that society, because sheep provided both wool for clothing and meat for food and religious sacrifices. But shepherds were not generally wealthy people. It would be today as if the angels announced the baby's birth to motodups or cyclo drivers. These are people who are familiar to us, they perform an important role in our society, but they are not generally wealthy or influential people. Not people we would expect to be the first to be informed that a king has been born—that God has come close to us in human form. But it is a symbol of just how close God came that first Christmas that Jesus was born to a shelterless, traveling couple, and that his first visitors were not the wealthy politician or merchants, but shepherds. God has come so close that he is available to *everybody*.

The fact that Jesus was totally human—so like us in every way—caused many people in his day to doubt that he was Immanuel. In John 1 we hear Nathaniel grumbling, "Can anything good come out of Nazareth?" In John 7 the people of Jerusalem debate among themselves, "Have the authorities really concluded that he is the Messiah? But we know where this man is from; when the Messiah comes, no one will know where he is from." In Mark 6 and Matthew 13 we hear people ask, "Where did this man get this wisdom and these miraculous powers? Isn't this the carpenter's son? Isn't his mother's name Mary, and aren't his brothers James, Joseph, Simon, and Judas? Aren't all his sisters with us? Where then did this man get all these things?" And so they took offense at him and refused to believe that

he was God With Us, because God had come so close as to seem indistinguishable at first glance. The book of Isaiah says, "He had no beauty or majesty to attract us to him, nothing in his appearance that we should desire him." Only when we look closer and hear his wisdom and watch his deeds and observe his sinlessness do we recognize that the scriptures that had predicted Immanuel have been fulfilled in this man.

The New Testament goes on to describe how close God has come to us in Jesus. The Apostle John begins his first letter by saying, "That which was from the beginning, which we have heard, which we have seen with our eyes, which we have looked at and our hands have touched—this we proclaim...." He begins his gospel by telling us that "The Word became flesh and made his dwelling among us. We have seen his glory, the glory of the One and Only, who came from the Father, full of grace and truth.... No one has ever seen God, but God the One and Only, who is at the Father's side, has made him known." When Thomas doubted that Jesus had been raised from the dead Jesus appeared to him and urged him to put his finger where the nails had been in Jesus' hands, and to thrust his hand into where the spear had pierced Jesus' side. That's very, very close. In fact, the book of Hebrews says that God's Son "had to be made like [us] in every way, in order that he might become a merciful and faithful high priest ... and ... make atonement for the sins of the people." As a result "we do not have a high priest who is unable to sympathize with our weaknesses, but we have one who has been tempted in every way, just as we are—yet was without sin." At Christmas we celebrate the birth of one whose title is Immanuel—God with us. The Great and Powerful God of Creation has indeed come very, very close.

All of this is Good News for us. All of this means we don't need to fear or seek help from all kinds of spirits and other forces—real or imagined. The Great God himself cares for us, and he is powerful to save. Jesus taught that God loves us so much that even the hairs on our heads are numbered. He told his disciples that "the Father [that is, God] himself loves you because you have loved me and have believed that I came from God." Therefore "my Father will give you whatever you ask in my name." Jesus promised that if anyone loved him he

would obey his teaching and "My Father will love him, and we will come to him and make our home with him." Our bondage to the spirits is broken because the Great God loves us and lives in us as Christians, and he is greater than any other power. Christmas is Good News—the Great God has come close and lives with all who accept the pardon purchased by his Son.

Have you accepted God's love to you in Jesus yet? Have you said, "All my life I have been serving shadows and spirits—either things that I have imagined but that aren't really there, or things that are evil and should not be served. But now I turn from them to the Great God who has come close and shown me who he is in Jesus"? Have you understood what Christmas is—not a fat man with a white beard in a red suit who gives presents, not a decorated tree and special songs, but the birthday of the man in whom God has come close?

This Christmas message that God has come close to us in the person of Jesus not only has something to say to people who are not Christians, but also to those of us who are. How do we Christians think of Christmas, and how do we celebrate it?

We are gathered today in a large stadium with many people in attendance. We have banners and music and dancing and a powerful sound system. We have invited dignitaries and special guests, and many of us are wearing our nice clothing. It is good for us to celebrate Christ's birth in this way, and show how important it is to us. It is good for us to meet together in a large meeting as Christians from different churches and denominations to show how our common faith in Jesus and love for him unites us, and is more important than the denominational differences that we sometimes allow to divide us. It is good to worship and be glad together like this in a big way.

But is that the only way we can celebrate Christmas? Is a big meeting the only way we can show how important it is to us that the Son of God has come among us to be our savior?

Let us remember that Christmas commemorates the coming of Immanuel—"God With Us." Let us remember that when God came to us in Christ he came close—not as presidents and kings and prime ministers do today, surrounded by guards to keep common people away, and dressed in fine clothing. He came close—born to a shelterless

couple, wrapped in strips of cloth, and laid in a box from which animals eat their food. His first visitors were shepherds. He looked so much like ordinary people and grew up in such an unimportant village that many could not believe he was anything special. John says he came so close that his eyes looked upon him and his hands touched him. Christmas is not primarily about big meetings and expensive programs, although, as I said, these are good and certainly have their place. Christmas is first of all God coming close to everyday people in the everyday concerns of their daily life.

So, as Christians, if we want our non-Christian neighbors to know this Jesus whom we love, we need to be little "Immanuels" to them. Jesus said to his apostles, "As the Father has sent me, so send I you." He sends us the same way God sent him—to live among people and show them by our lives what God is like. To care for them where we can in their everyday needs and problems.

So when a Christian takes a meal to a young mother dying of AIDS, that is Christmas for that woman. That is someone coming close to her in her poverty, and ministering to her in God's name. When a church gets together and decides to clean up its neighborhood streets, or teach local street children how to read, or donate rice to a family that lost their whole crop to a flood, that is showing what Christmas is. God coming close to us where we are, where we can see what he is like and experience his practical love and care. Our celebrations like this one can be very encouraging to us and honoring to God. But if that is all we do then our non-Christian neighbors are likely to say, "The Christians are celebrating one of their religious festivals again. That has nothing to do with me; I have my own religion and festivals." On the other hand, if we serve them up close, where they are, in practical and meaningful ways, then they will understand that Christmas is the coming of Immanuel—"God With Us"—right to where we live and work and play and struggle. Perhaps in time they will feel encouraged to abandon their fear of lesser spirits, because they will realize that the Great God himself has come close.

សំណុំនិក្ខុំ ៤/២ (កក្កដា ២០០៣)៖ ៣៤-៤៨



# ព្រះជាម្ចាស់យាងមកកៀកជិតនឹងអ្នកហើយ

*បណ្ឌិត រ៉ាស់សែល បាវឌើស*

នៅក្នុងទីក្រុងអានុរ៉ាតបាពូរ៉ា ដែលស្ថិតនៅក្នុងភាគខាងជើងនៃប្រទេសស្រីលង្កា មានកោះមួយលាតសន្ធឹងបង្ហាញរាងយ៉ាងស្រស់ត្រកាល ដែលនៅលើនោះមានទីសក្ការៈបូជាដ៏ពិសិដ្ឋបំផុត ។ ដើមពោធិមួយដើម ដុះនៅទីនោះដែលមានមនុស្សជំណាលតគ្នាថា នៅក្រោមដើមពោធិ៍នោះហើយដែលព្រះពុទ្ធបានត្រាស់ដឹងជាព្រះ ។ គេបានធ្វើរបងដែកព័ទ្ធជុំវិញដើមឈើដ៏ចំណាស់ និងពិសិដ្ឋនោះ និងមានពួកអ្នកធ្វើធម្មយាត្រារាប់រយនាក់មកកាន់កន្លែងនោះជារៀងរាល់ថ្ងៃដើម្បីមកតាំងភាវនានៅមុខដើមឈើនោះ ។ នៅពេលថ្មីនេះពេលដែលខ្ញុំបានទៅទស្សនាកន្លែងនោះ ខ្ញុំបានឃើញមនុស្សជាច្រើនអង្គុយបិទភ្នែក លើកដៃសំពះទៅដើមឈើនោះ ។ ខ្ញុំបានសួរទៅអ្នកនាំផ្លូវរបស់ខ្ញុំថា "តើពួកគេកំពុងសំពះបួងសួង

---

*អត្ថបទនេះបានអធិប្បាយជាលើកដំបូងនៅក្នុងពិធីបុណ្យណូអែលនៅក្នុងទីក្រុងភ្នំពេញ ថ្ងៃទី ២០ ខែធ្នូ ឆ្នាំ ២០០២ ។*

ទៅព្រះពុទ្ធឬ?” នាងបានឆ្លើយថា “ទេ” ។ “ព្រះពុទ្ធបានយាងផុតពីជីវិតនេះទៅហើយ គឺព្រះអង្គយាងចូលនិព្វាន ។ ព្រះអង្គទ្រង់មិនបានព្រះសណ្តាប់ឮ ឬក៏អាចឆ្លើយតាមពាក្យបួងសួងនោះបានឡើយ ។ មនុស្សទាំងអស់នេះកំពុងតែតាំងភាវនាសញ្ជឹងគិតចំពោះធម៌របស់ព្រះពុទ្ធដែលទ្រង់សំដែង និងកំពុងបង្ហាញការគោរពដល់ធម៌ទាំងនោះ។ បើគេត្រូវការអ្វីមួយ និងចង់បួងសួងនោះ គេត្រូវបួងសួងទៅដល់ទេវតា” ។

មានរឿងដូចគ្នានេះដែរ កើតមានឡើងនៅកន្លែងផ្សេងទៀតនៅក្នុងលោកយើងនេះ និងចំពោះសាសនាដទៃទៀតក្រៅពីព្រះពុទ្ធសាសនា ។ មានមនុស្សជាច្រើនដឹងជាក់នៅក្នុងចិត្តថា មានព្រះអាទិករ ដែលជាអ្នករៀបចំតាក់តែងបង្កើតនូវរបស់សព្វសារពើដែលយើងអាចមើលឃើញ ។ ពិភពលោកនេះមានការរចនារៀបចំយ៉ាងល្អ និងជីវិតដែលកំពើករស់នៅលើផែនដីទៀតសោត ក៏មានលក្ខណៈចំរុះផងដែរ ។ និយាយឲ្យងាយស្តាប់ទៅ របស់ទាំងអស់កើតឡើងដោយសារឱកាសចៃដន្យណាមួយ ឬបានមកពីដំណើរច្រំដែលវិលចុះវិលឡើងគ្មានទីបញ្ចប់របស់ប្រវត្តិសាស្ត្រ ។ បើខ្ញុំប្រទះឃើញកំព្យូទ័រមួយគ្រឿង ខ្ញុំដឹងថាប្រាកដជាមានរណាម្នាក់ជាអ្នកគ្រោង និងបង្កើតតាមគំរោងដែលគេគ្រោងយ៉ាងល្អិតល្អន់ជាមិនខាន នាឡិការអាចកើតឡើងបានលុះត្រាតែមានជាងជាអ្នកបង្កើតវាឡើង ម៉ូតូត្រូវតែកើតចេញពីអ្នកដែលផលិតម៉ូតូ ។ ដូចគ្នាដែរ គ្រាប់ពូជស្រូវដែលអាចចាក់ឫសដើម្បីបឺតយកជាតិទឹកនោះ និងដើម្បីឲ្យអាចលាស់ស្លឹកទទួលយកពន្លឺថ្ងៃ និងខ្យល់ សត្វស្លាបដែលស្រែកយំកញ្ជ្រៀវនៅលើអាកាសព្រមទាំងមនុស្សដែលអាចគិត និងច្នៃធ្វើរបស់សព្វសារពើទាំងអស់នោះ ក៏មានអ្នកគ្រោងបង្កើត និងអ្នកបង្កើតដ៏ឈ្លាសវៃលៃលកច្នៃឲ្យកើតមកដែរ ។ យើងកើតមកនេះ មិនមែនដោយចៃដន្យនោះឡើយ ហើយក៏មានមនុស្សជាច្រើនទទួលស្គាល់ការនោះដែរ ។ ប៉ុន្តែមនុស្សជាច្រើនដែលដឹងថា មានព្រះអាទិករបង្កើតគេមក នោះខ្លាចថាព្រះអង្គគង់នៅឆ្ងាយពីគេណាស់ប្រហែលជាព្រះអង្គមិន

បានយកព្រះទ័យទុកដាក់និងយើងឡើយ ហើយយើងក៏មិនអាចស្គាល់ព្រះអង្គបានដែរ ។ យើងជាស្នាព្រះហស្តព្រះអង្គទៅវិញទេ ដែលមិនស្គាល់ព្រះអង្គ ។ ដូច្នេះ បើសិនជាយើងត្រូវការជំនួយនៅក្នុងជីវិតរស់នៅប្រចាំថ្ងៃរបស់យើងនោះ យើងត្រូវខិតចូលទៅកៀកកិតនឹងព្រះអង្គដោយមាននូវភាពជិតស្និទ្ធខាងឯវិញ្ញាណ ។

មនុស្សយើងខ្លះមានការភ័យខ្លាចខ្មោច ឬវិញ្ញាណដូនតាដែលបានចែកស្ថានទៅហើយ ដោយខ្លាចវិញ្ញាណទាំងនោះមកធ្វើបាបដល់គេ អ្នកខ្លះទៀតនោះក៏ខំសែនព្រេនដល់អ្នកតា ជនជាតិថៃគេសែនព្រេនដល់វិញ្ញាណ ដែលហៅថា "ភី"[១] នៅក្នុងប្រទេសភូមាគេយកផ្លែដូង និងក្រណាត់ក្រហមសែនដល់វិញ្ញាណឈ្មោះថា "ណាត់" ។ ពួកអ្នកដែលកាន់សាសនាឥស្លាមវិញ គេមិនខ្វល់ក្នុងការសែនព្រេនដល់វិញ្ញាណដែលហៅថា "ចីន" នោះឡើយ ។ បើរៀបរាប់ទៅឃើញថា មានច្រើនថែមទៀត ។ អារម្មណ៍ជារួមរបស់មនុស្សទាំងអស់នៅលើសកលលោកយើងនេះ គឺផ្ដោតលើព្រះដែលសំខាន់បំផុត និងមានអំណាចបំផុត គឺជាព្រះដ៏ធំឧត្តមដែលបានបង្កើតយើង ដោយហេតុនោះបានជាយើងគិតថា ព្រះអង្គនោះធំណាស់ ឬនៅឆ្ងាយពីយើងណាស់ ឬព្រះអង្គលែងខ្វល់ និងថែទាំមនុស្សដែលព្រះអង្គបង្កើតមកហើយ ទើបបានជាយើងខំស្វែងរកជំនួយពីកន្លែងផ្សេងៗ ដែលគ្មានអំណាចដូចជាព្រះអង្គវិញ ។

យើងប្រទះឃើញហេតុការណ៍បែបនេះនៅក្នុងព្រះគម្ពីរដែរ ។ កំលោះវ័យក្មេងជនជាតិអ៊ីស្រាអែលម្នាក់ឈ្មោះ ដានីយ៉ែល ។ គាត់បានថ្វាយបង្គំដល់ព្រះដ៏ពិត និងជាព្រះដ៏ធំឧត្តម ប៉ុន្តែប្រទេសជាតិត្រូវទទួលបរាជ័យនៅក្នុងសង្គ្រាមដោយចាញ់ពួកខ្មាំងសត្រូវរបស់ខ្លួន គឺពួកបាប៊ីឡូន ។ ហេតុដូច្នេះ គេបានបង្ខំដានីយ៉ែលឲ្យទៅបំរើដល់ស្តេចសាសន៍ដទៃនៅក្នុងក្រុងបាប៊ីឡូន ។ នៅពេល

---

[១] ភី ជាពាក្យថៃ ដែលមានន័យជាភាសាខ្មែរថា ខ្មោច

យប់មួយនោះ ស្ដេចទ្រង់ផ្ទំលង់លក់ទៅ ក៏យល់សប្តិ ហើយស្ដេចចង់ដឹងពីអត្ថន័យនៃការយល់សប្តិនោះ ។ ព្រះអង្គក៏បានកោះហៅពួកអ្នកប្រាជ្ញនោះមកដោយមានបន្ទូលថា "ចូរប្រាប់អញមកមើល តើអញយល់សប្តិអំពីអ្វី ហើយសូមប្រាប់មកអញមើល តើកាត់ស្រាយយ៉ាងម៉េច?" ។ បណ្ដាពួកអ្នកប្រាជ្ញបានឆ្លើយថា "ឱព្រះករុណាថ្លៃវិសេស សូមព្រះអង្គមានបន្ទូលប្រាប់មកយើងចុះ នោះយើងនឹងកាត់ស្រាយទូលដល់ព្រះអង្គក្រាបទូល" ។ ស្ដេចឆ្លើយថា "ទេ! សូមប្រាប់មកអញ ថាអញយល់សប្តិពីអ្វី ។ ពេលនោះអញនឹងដឹងថា ឯងរាល់គ្នាមិនប្រឌិតរឿងនៅក្នុងគំនិតរបស់ឯង តែសូមប្រាប់ពីការកាត់ស្រាយសប្តិដ៏ត្រឹមត្រូវប្រាប់ដល់អញ" ។ ពួកអ្នកប្រាជ្ញនិយាយទាំងស្រងាកចិត្ត ទូលទៅស្ដេចថា "គ្មានមនុស្សណាម្នាក់នៅលើផែនដីនេះ អាចធ្វើបាននូវអ្វីដែលព្រះអង្គចង់បាននោះឡើយ! ទោះបីជាមានអ្នកខ្លាំងពូកែយ៉ាងណា ក៏គ្មាននរណាធ្លាប់សួរនូវរឿងចម្លែក បែបនេះបានដែរ ទោះអ្នកនោះជាអ្នកប្រើមន្តអាគម ឬគ្រូអាបធ្មប់ ឬអ្នកសិក្សាពីផ្កាយមើលជោគជតារាសីក៏ដោយ ។ អ្វីដែលព្រះករុណាមានបន្ទូលនោះ គឺពិបាកជ្រុលពេកហើយ ។ គ្មាននរណាម្នាក់អាចកាត់ស្រាយថ្វាយព្រះអង្គបានឡើយ លើកលែងតែព្រះប៉ុណ្ណោះ ហើយអ្នកដែលអាចធ្វើការនោះ មិនបានរស់នៅក្នុងចំណោមយើងទេ" ។ តើយើងបានឮនូវអ្វីដែលពួកអ្នកប្រាជ្ញទាំងអស់នោះបាននិយាយឬទេ? មានព្រះដែលឈ្លាសវៃ និងមានអំណាចចេស្ដា និងសូម្បីតែរឿងរ៉ាវបែបដូចជាអ្វីដែលមនុស្សបានយល់សប្តិនោះដែរ ។ ប៉ុន្តែព្រះទាំងអស់នោះនៅឆ្ងាយពីយើង ហើយក៏មិនមែនរស់នៅជាមួយយើង ឬក៏អាចនិយាយមកកាន់យើងទៀតផង យើងគ្មានផ្លូវណាដែលអាចឲ្យយើងទាក់ទងជាមួយព្រះទាំងនោះបានឡើយ ។ នៅពេលដែលយើងមានបញ្ហា យើងត្រូវស្វែងរកជំនួយពីកន្លែងដែលមិនសូវមានអំណាចចេស្ដាប៉ុន្មាន (ជួនកាលវិញ្ញាណនោះដែលយើងចង់ឲ្យជួយនោះ ជាវិញ្ញាណក្លែងក្លាយទៀតផង) ។

ដូច្នេះ នេះជាផ្នត់គំនិតដែលចាក់ស្រេះជាប់នៅក្នុងប្រវត្តិសាស្ត្រ ដែលជឿថាមានព្រះដ៏ធំឧត្តម (ឬយ៉ាងហោចណាស់ក៏ជឿថាមានព្រះដែរ) ។ តែការដែលជឿនោះគឺថា ព្រះអង្គធំពេក ឬនៅឆ្ងាយពេក ។ យើងមិនអាចទាក់ទងព្រះអង្គបានឡើយ ព្រះអង្គក៏មិនអាចជួយយើង ឬព្រះអង្គនឹងមិនជួយយើងឡើយ ។

ការដែលយើងឃ្លាតឆ្ងាយពីព្រះដែលឈ្លាសវៃ និងមានបុទ្ធិចេស្តាដែលជួយនោះ គឺអាចជាការមួយគួរឲ្យយើងភ័យខ្លាចទៅវិញទេ ។ ខ្ញុំបានអាននូវរឿងរ៉ាវនៃជីវិតជាច្រើននៅក្នុងស្រុកខ្មែរក្រោមរបប ខ្មែរក្រហម ហើយខ្ញុំទើបចាប់ផ្តើមអានរឿងមួយផ្សេងទៀត ។ នៅក្នុងរឿងនោះ អ្នកនិពន្ធជាក្មេងស្រីអាយុប្រាំបួនឆ្នាំដែលជួបនូវភព្វវាសនាអាក្រក់គឺបានឆ្លងកាត់ថ្ងៃ ១៧ មេសា ឆ្នាំ១៩៧៥ នៅពេលដែលពួកទាហាន ប៉ុល ពត ជម្លាសអ្នកទីក្រុងភ្នំពេញឲ្យទៅរស់នៅតាមខេត្ត ។ នៅពេលដែលក្មេងស្រីនេះ និងគ្រួសាររបស់នាងរត់កាត់ហ្វូងមនុស្សដែលពពាក់ពពូនរត់លួនគេចចេញពីការប្រយុទ្ធគ្នារបស់ពួកខ្មែរក្រហម ខណៈពេលដែលចេញពីទីក្រុង គ្រួសារនាងបានប្រទះឃើញក្មេងប្រុសអាយុ បីឆ្នាំ ម្នាក់កំពុងវង្វេងបាត់ឪពុកម្តាយ ឈរយំស្រែករកឪពុកម្តាយរបស់គេ ។ ក្មេងប្រុសនោះកំពុងវង្វេងបាត់ឪពុកម្តាយ ឈរតែម្នាក់ឯងក្នុងពិភពថ្មីចម្លែកពោរពេញដោយគ្រោះថ្នាក់ និងគួរឲ្យភ័យខ្លាចបំផុត ។ ឪពុកម្តាយដែលជាទីអាងមាំមួន ធ្លាប់តែមានភាពកក់ក្តៅឲ្យគាត់នោះ និងការពារគាត់បានបាត់ស្រមោលសូន្យឈឹងទាំងអស់ ។

យើងទាំងអស់គ្នា ពេលខ្លះមានអារម្មណ៍ដូចជាក្មេងនោះអ៊ីចឹងដែរ ។ យើងយល់ថា យើងកំពុងនៅតែឯង ត្រូវពឹងផ្អែកលើប្រាជ្ញាផ្ទាល់ខ្លួនដែលមានព្រំដែនកំណត់ (ហើយពេលខ្លះក៏មិនត្រឹមត្រូវទៀត) យើងនឹងត្រូវពឹងលើធនធានទាំងឡាយនៅក្នុងលោកដែលយើងកំពុងជួបប្រទះនូវការរាំងស្ងួត និងទុរ្ភិក្សនិងសង្គ្រាម អំពើពុករលួយ ភេវរកម្ម ជម្ងឺអេដស៍ និងកុមារមានជម្ងឺ ។ យើងស្រែកអំពាវនាវតែគ្មានអ្នកណាជួយយើងសោះ ។ ព្រះដ៏ធំឧត្តម បើសិនជាមានមែន ព្រះអង្គនៅឆ្ងាយ និងស្ងាត់ឈឹងទៅទៀត ។ ដូច្នេះ យើងត្រូវតែស្រវាអ្វី

ក៏ដោយដែលនៅជិតដៃ ដែលយើងគិតថាអាចជួយយើងបាន មិនខុសគ្នានិងមនុស្សលង់ទឹកឡើយ ដែលស្រវារកអ្វីក៏ដោយឲ្យតែនៅជិតដៃ ដើម្បីជួយឲ្យគាត់អាចបណ្តែតខ្លួនបាន ។

មានការពិតខ្លះៗដែរ ដែលថាព្រះដ៏ធំឧត្តមគង់នៅឆ្ងាយពីយើង ។ ពីមុននោះមិនដូច្នេះឡើយ តែឥឡូវនេះពិតដូច្នេះមែន ។ នៅពេលដែលព្រះបង្កើតមនុស្សប្រុស និងមនុស្សស្រីដំបូង ព្រះធ្លាប់យាង និងជជែកជាមួយពួកគេ ។ ប៉ុន្តែនៅថ្ងៃមួយ គេបានបះបោរទាស់ទទឹងទៅនឹងបទបញ្ញត្តិរបស់ព្រះអង្គ ដោយហេតុនោះហើយ ទើបគេត្រូវបាត់បង់នូវសម្ពន្ធភាពជិតស្និទ្ធជាមួយនឹងព្រះដ៏ធំឧត្តមប្រកបដោយបុទ្ធានុភាពអស្ចារ្យនោះទៅ ។ ជាច្រើនសតវត្សក្រោយមកព្រះជាម្ចាស់មានបន្ទូលទៅកាន់ប្រជារាស្ត្ររបស់ទ្រង់ គឺប្រជារាស្ត្រអ៊ីស្រាអែលថា "ពិតប្រាកដមែន ព្រោះព្រះពាហុនៃព្រះយេហូវ៉ា មិនមែនរួញខ្លីក្នុងការសង្គ្រោះនោះឡើយ ព្រះកាណ៌របស់ព្រះអង្គក៏មិនធ្ងន់ដែលស្តាប់មិនឮនោះដែរ ។ ប៉ុន្តែដោយព្រោះអំពើរំលងរបស់អ្នករាល់គ្នា បានលាក់ព្រះភ័ក្ត្រព្រះជាម្ចាស់ពីឯងរាល់គ្នា ដោយហេតុនេះហើយ ទើបព្រះអង្គមិនអាចស្តាប់ឯងឮ" ។ គឺប្រៀបដូចជាលោកអ្នក និងខ្ញុំមិនបានពាក់ស្បែកជើងចូលទៅក្នុងផ្ទះ ដោយព្រោះថាយើងដើរកាត់ភក់ល្បាប់ទឹកស្អុយនៅតាមផ្លូវនោះ យើងត្រូវដោះស្បែកជើងនោះដាក់នៅខាងក្រៅផ្ទះ ចំណែកឯព្រះជាម្ចាស់វិញ ទ្រង់ជាព្រះបរិសុទ្ធស្អាត នោះព្រះអង្គក៏មិនអនុញ្ញាតឲ្យមានអំពើកំណាច និងការបះបោរណាមួយមកនៅចំពោះព្រះវត្តមានរបស់ព្រះអង្គបានឡើយ ។ អំពើបាបរបស់យើងបានញែកយើងចេញពីព្រះរបស់យើង អំពើបាបនោះឯងដែលបាំងព្រះភ័ក្ត្ររបស់ព្រះអង្គ ទើបព្រះអង្គទ្រង់ព្រះសណ្តាប់យើងមិនឮ ។ យើងទាំងអស់គ្នាប្រៀបដូចជាកូនក្មេងអាយុបីឆ្នាំដែលស្រែកដង្ហោយហៅរកឪពុកម្តាយ តែគ្មានរណាស្តាប់ឮសោះ ហើយកូននោះឯងកំពុងស្ថិតនៅក្នុងពិភពលោកមួយដែលកំពុងច្របូកច្របល់ ។

ប្រសិនបើនេះជាព្រះរាជសារតែមួយគត់ដែលព្រះគម្ពីរបានបង្រៀននោះ តាមពិតទៅជារឿងមួយគួរឲ្យសោកស្តាយមែនទែន ។ ប៉ុន្តែមានការមួយដែលកើតឡើង គឺព្រះរាជកំណើតរបស់ព្រះយេស៊ូ ។ ថ្ងៃនោះ គឺជារឿងរ៉ាវស្តីពីព្រះដ៏ធំឧត្តម គឺជាព្រះដែលបានបង្កើតយើងមក ព្រះអង្គស្គាល់យើង និងព្រះអង្គជាព្រះឈ្លាសវៃ និងមានចេស្តាគ្រប់គ្រាន់ដើម្បីជួយយើង ព្រះអង្គនោះឯងយាងមកជិតយើង ។ តាមពិតទៅព្រះអង្គអាក់អន់ស្រពន់ព្រះទ័យដោយព្រោះអំពើបាបរបស់យើងលើសជាងការដែលយើងពាក់ស្បែកជើងកខ្វក់ទៅទៀត តែដោយសារសេចក្តីស្រឡាញ់របស់ព្រះអង្គនោះឯងទើបព្រះអង្គយាងមកជិតយើង ។ ព្រះអង្គបានយាងមកជិតដើម្បីបង្ហាញឲ្យយើងស្គាល់ថា ព្រះអង្គជាអង្គដែលអាចសំអាតយើងពីគ្រប់អំពើបាប និងដើម្បីជួយផ្សះផ្សាយើងឲ្យមានភាពជិតស្និទ្ធដូចដែលយើងធ្លាប់មានពីមុនមកជាមួយព្រះជាម្ចាស់ ។ ព្រះគម្ពីរសញ្ញាចាស់បានទស្សន៍ទាយពីអ្នកដែលមកជួយរំដោះដែលមានព្រះនាមថា “អេម៉ាញូអែល” ។ “អេម៉ាញូអែល” គឺជាភាសាហេព្រើរ ដែលមានពាក្យបីម៉ាត់តូចៗរួមជាមួយគ្នាមានន័យថា “ព្រះគង់នៅជាមួយយើង” ។ នៅក្នុងគម្ពីរសញ្ញាថ្មីបានប្រាប់ពីដំណើររឿងនៃព្រះដែលមានព្រះនាមថា អេម៉ាញូអែល មានន័យថា ព្រះជាម្ចាស់គង់នៅជាមួយយើងនេះ ត្រូវយាងមកដោយរបៀបណា? មកក្នុងមធ្យោបាយណាទៅ និងតើជិតស្និទ្ធយ៉ាងណាទៅ ដែលព្រះអាទិករបង្កើតរបស់សព្វសារពើយាងមករកយើង?

អស់រយៈពេលពីរសប្តាហ៍ ដែលខ្ញុំបានចូលរួមសន្និបាតផ្នែកព្រះពុទ្ធសាសនានៅក្នុងព្រះបរមរាជវាំង និងនៅសាលចតុមុខ ។ សម្តេចសង្ឃ និងមន្ត្រីសង្ឃជាន់ខ្ពស់ពីបណ្តាប្រទេសទាំង១៦បានមកចូលរួមនៅទីនោះ ។ ក្នុងពេលចាប់ផ្តើមពិធីនោះ ព្រះមហាក្សត្ររបស់យើង ព្រះបាទ នរោត្តម សីហនុ បានថ្លែងសន្ទរកថា ហើយបន្ទាប់មក សម្តេចព្រះ អគ្គមហេសី និងទ្រង់គង់នៅលើកាំជណ្តើរនៃវត្តប្រាសាទខេមរិនដើម្បីគង់ប្រថាប់រួមជាមួយ នឹងគណៈប្រតិភូ ។

ខ្ញុំបានឃើញព្រះអង្គផ្ទាល់ភ្នែក ប៉ុន្តែនៅចំងាយប្រហែលជាពីររយម៉ែត្រ ។ ព្រះមហាក្សត្រមានមន្ត្រីជាន់ខ្ពស់ជាច្រើន នៅឈររអម ។ អ្នកទាំងនោះជាភ្ញៀវដែលគេបានអញ្ជើញមកឲ្យចូលរួម និងជាកងរក្សាព្រះអង្គ ។ ភាគច្រើនបំផុតនោះគឺខ្ញុំមិនដែលបាននៅជិតព្រះមហាក្សត្រសោះ ។ អ្វីដែលជិតបំផុតដែលខ្ញុំបានទទួលនោះគឺ ខ្ញុំបានឮសំឡេងរបស់ព្រះអង្គតាមវិទ្យុ ឬបានឃើញព្រះឆាយាលក្ខណ៍របស់ព្រះអង្គតាមសារពត៌មាន ។ កាលពី២ឆ្នាំកន្លងទៅ ខ្ញុំបានឃើញព្រះមហាក្សត្រនៅថ្ងៃបុណ្យឯករាជ្យ ប៉ុន្តែនៅថ្ងៃសន្និបាតនេះ គឺជាគ្រាដំបូងដែលខ្ញុំបានឃើញច្បាស់ និងបានឮទ្រង់មានបន្ទូល ។ ដូច្នេះ នៅថ្ងៃទី ៥ ខែធ្នូ ឆ្នាំ២០០២ កន្លងទៅនេះ ខ្ញុំគិតថាខ្ញុំបាននៅជិតព្រះមហាក្សត្រនៃប្រទេសកម្ពុជាបានមកកៀកកិត... ប៉ុន្តែ មិនបាននៅកៀកកិតនឹងព្រះអង្គឡើយ ។

តើព្រះមហាក្សត្រនៃស្ថានសួគ៌យាងមកជិតប៉ុណ្ណាទៅ? បើសិនជាស្តេចនៅលើផែនដីទាំងអស់នោះកម្រមកជិតយើង ហើយពេញទៅដោយមនុស្សថ្នាក់កំពូលៗចាំហែរហមអមដំណើរ ព្រមទាំងការពារមិនឲ្យយើងចូលទៅជិតបានទៅហើយ ចុះទំរាំព្រះជាម្ចាស់ដែលជាព្រះអាទិករបង្កើតលោកទាំងមូល ពិតប្រាកដណាស់ទ្រង់ក៏នៅឆ្ងាយពីយើងលើសពីនេះទៅទៀតដែរ? ប៉ុន្តែដោយសារតែបុណ្យព្រះរាជកំណើតរបស់ព្រះអង្គ ដំណើររឿងនោះបានបង្ហាញពីរបៀបដែលព្រះជាម្ចាស់បានយាងមកជិតយើងគឺជិតបំផុត ។

ព្រះអង្គដែលមានព្រះនាមថា "អេម៉ាញូអែល" ដែលស្រាយថា ព្រះអង្គគង់ជាមួយយើងគឺបានប្រសូត្រមកជាទារកហើយ ។ តែព្រះអង្គមិនបានប្រសូត្រនៅក្នុងព្រះរាជវាំង ឬជារាជបុត្ររបស់វង្សានុវង្សរបស់អង្គក្សត្រាណាមួយនោះឡើយ បើសិនជាព្រះអង្គប្រសូត្រនៅក្នុងរាជវាំង នោះមានមនុស្សតែមួយចំនួនតូចតែប៉ុណ្ណោះ ដែលមានឯកសិទ្ធិសង្ឃឹមថាអាចចូលទៅគាល់ព្រះអង្គបាន ។ ព្រះអង្គបានប្រសូត្រមកក្នុងគ្រួសារក្រីក្រមួយដែលកំពុងតែធ្វើដំណើរ ហើយរកកន្លែងស្នាក់នៅក៏គ្មានផង ។ សូម្បីតែរកកន្លែងសំរាប់មាតារបស់ព្រះអង្គសម្រាល

ព្រះអង្គក៏គ្មានដែរ ។ ដូច្នេះ មាតារបស់ព្រះអង្គត្រូវសម្រាលព្រះអង្គនៅក្នុងក្រោលសត្វ ។ គឺអាចជាកន្លែងក្រោលម៉្យាង ឬក៏ជានៅក្នុងល្អាងអ្វីមួយ ឬក៏អាចជានៅកន្លែងខាងក្រៅ ដែលជាកន្លែងដាក់ចំណីសត្វ ។ ប៉ុន្តែបន្ទាប់ពីព្រះយេស៊ូបានប្រសូត្ររួចមក មាតាព្រះអង្គបានផ្តេកទ្រង់នៅក្នុងស្នូកសត្វ ។ បើសិនជាព្រះឱរសយេស៊ូនេះ ពិតជាអេម៉ាញូអែលមែន អ៊ីចឹងព្រះជាម្ចាស់ពិតជាយាងមកជិតយើងមែនហើយ ។

អ្នកដែលបានមកសួរសុខទុក្ខព្រះឱរសមុនគេបង្អស់នោះ មិនមែនជានាយករដ្ឋមន្ត្រី ឬជាមន្ត្រីជាន់ខ្ពស់ផ្នែកតុលាការឡើយ តែជាពួកអ្នកគង្វាល ។ ពួកអ្នកគង្វាលជាស្រទាប់វណ្ណៈដ៏សាមញ្ញបំផុតនៅក្នុងប្រទេសអ៊ីស្រាអែលសម័យនោះ ។ គេមានតួនាទីសំខាន់នៅក្នុងសង្គម ពីព្រោះចៀមផ្តល់រោមសំរាប់ធ្វើសំលៀកបំពាក់ និងសាច់សំរាប់ជាអាហារ និងសំរាប់ធ្វើយញ្ញបូជាផ្នែកសាសនា ។ ប៉ុន្តែពួកគង្វាលជាទូទៅ មិនមែនជាមនុស្សមានសម្បត្តិស្តុកស្តម្ភនោះឡើយ ។ បើប្រៀបនឹងសម័យសព្វថ្ងៃនេះវិញ ទេវតាអាចនឹងប្រកាសប្រាប់ពីដំណឹងនៃបុត្រតូចនោះទៅដល់ពួកអ្នករត់ម៉ូតូឌុប និងអ្នកធាក់ស៊ីក្លូ ។ ទាំងនេះគឺជាមនុស្សដែលមានឋានៈស្រដៀងនឹងយើងដែរ ដែលគេមានតួនាទីសំខាន់នៅក្នុងសង្គមរបស់យើង តែជាទូទៅគេមិនមានទ្រព្យសម្បត្តិស្តុកស្តម្ភ ឬក៏មិនមែនជាមនុស្សមានអំណាចប៉ុន្មានដែរ ក្នុងន័យនេះ បានន័យថាព្រះជាម្ចាស់យាងមករកយើងដោយយកនិស្ស័យជាមនុស្ស ។ ប៉ុន្តែការនេះគឺជានិមិត្តសញ្ញាដែលបង្ហាញពីរបៀបដែលព្រះជាម្ចាស់យាងមកជិតយើងនៅថ្ងៃកំណើតរបស់ព្រះអង្គលើកដំបូង ព្រះអង្គបានកើតនៅក្នុងគ្រួសារដែលគ្មានទីជំរក គឺកើតចំពេលគ្រួសារនេះកំពុងធ្វើដំណើរ ហើយភ្ញៀវដំបូងគេដែលមកសួរសុខទុក្ខនោះ មិនមែនជាអ្នកនយោបាយ អ្នកជំនួញដែលមានសម្បត្តិស្តុកស្តម្ភ ប៉ុន្តែជាអ្នកគង្វាល ។ ព្រះអង្គយាងមកជិតប្រយោជន៍ឲ្យមនុស្សគ្រប់រូបអាចចូលទៅគាល់ព្រះអង្គបានគ្រប់គ្នា។

ហេតុការណ៍មួយដែលថា ព្រះយេស៊ូជាមនុស្សសុទ្ធសាធដូចជាយើងរាល់គ្នាបេះបិទនោះ បានធ្វើឲ្យមនុស្សជាច្រើននៅក្នុងសម័យនោះសង្ស័យភាពអេម៉ាញូអែលរបស់ព្រះអង្គ ។ នៅក្នុងយ៉ូហានជំពូក១ យើងឮ ណាថាណែលរអ៊ូថា "តើអាចមានអ្វីល្អទេដែលចេញមកពីណាសារ៉ែត?" នៅក្នុងយ៉ូហាន ជំពូក៦ ពួកអ្នកស្រុកក្រុងយេរូសាឡិម បានពិភាក្សាវែកញែកដោះស្រាយក្នុងចំណោមពួកគេថា "តើពួកអាជ្ញាធរពិតជាសន្និដ្ឋានថា អ្នកនោះជាព្រះមែស៊ីមែនឬ? តែយើងដឹងថា បុរសនោះមកពីណា ពេលដែលព្រះមែស៊ីយាងមកនោះគ្មាននរណាម្នាក់ដឹងថា ព្រះអង្គយាងមកពីណាឡើយ" ។ នៅក្នុងម៉ាកុស ជំពូក៦ និងម៉ាថាយ១៣ យើងបានឮមនុស្សសួរគ្នាថា "មនុស្សនេះបានទទួលប្រាជ្ញាមកពីណា និងអំណាចចេស្ដាអាចធ្វើការអស្ចារ្យទាំងនេះបានមកពីណា? តើអ្នកនេះមិនមែនជាកូនជាងឈើទេឬអី? និងគាត់មិនមានប្អូនប្រុសឈ្មោះយ៉ាកុប យ៉ូសែប ស៊ីម៉ូន និងយូដាសទេឬអី? តើមិនមែនទេឬអី ដែលប្អូនស្រីៗរបស់គាត់នៅជាមួយយើងនោះ? អ៊ីចឹង តើបុរសម្នាក់នេះបានរឿងទាំងនេះមកពីណា?" ។ ដោយហេតុដូច្នេះហើយ បានជាគេមិនសូវសប្បាយចិត្តនឹងព្រះអង្គព្រមទាំងមិនជឿថា ព្រះអង្គជាព្រះដែលគង់នៅជាមួយយើង ពីព្រោះថាព្រះជាម្ចាស់បានមកជិតយើងពេក នៅពេលដែលយើងមើលទៅហាក់បីដូចជាពិបាកបែងចែកឲ្យបានដឹងច្បាស់ តើមែន ឬមិនមែននោះ ។ គម្ពីរអេសាយបានចែងថា "ព្រះអង្គមិនមានអ្វីដែលល្អ ឬបារមីដែលអាចទាក់ទាញយើងទៅចំពោះទ្រង់នោះទេ គឺទ្រង់គ្មានរូបអង្គខាងក្រៅអ្វីសោះដែលទាក់ទាញធ្វើឲ្យយើងប្រាថ្នាចង់បានព្រះអង្គ" ។ គឺនៅពេលដែលយើងសំឡឹងទៅជិតព្រះអង្គទៅៗ ហើយឮពីប្រាជ្ញាញាណរបស់ព្រះអង្គ និងសំលឹងទៅលើការប្រព្រឹត្តិរបស់ទ្រង់ ហើយសង្កេតទៅលើភាពគ្មានបាបសោះរបស់ព្រះអង្គនោះ ទើបយើងទទួលស្គាល់ថា ព្រះបន្ទូលដែលបានទាយទុកមកអំពី អេម៉ាញូអែល គឺត្រូវបានសំរេចនៅក្នុងអង្គមួយនេះឯង ។

គម្ពីរសញ្ញាថ្មីពិពណ៌នាបន្តអំពីកៀកកិតយ៉ាងណាទៅ ដែលព្រះទ្រង់យាងមកជិតពួកគេតាមរយៈអង្គព្រះយេស៊ូ ។ លោកសាវ័ក យ៉ូហាន ចាប់ផ្តើមសៀវភៅដំបូងរបស់គាត់ដោយនិយាយថា "ឯសេចក្តីដែលមានតាំងពីដើមមក ដែលយើងខ្ញុំបានឮ ហើយភ្នែកបានឃើញ ក៏បានមើល ហើយដៃបានប៉ះពាល់ខាងឯព្រះបន្ទូលជីវិត..." គាត់បានផ្តើមនៅក្នុងគម្ពីរដំណឹងល្អដោយប្រាប់យើងថា "ព្រះបន្ទូលក៏ត្រឡប់ជាសាច់ឈាម ហើយបានស្នាក់នៅជាមួយនឹងយើងរាល់គ្នា យើងរាល់គ្នាបានឃើញសិរីល្អទ្រង់ គឺជាសិរីល្អនៃព្រះរាជបុត្រាតែមួយដែលមកពីព្រះវរបិតា មានពេញជាព្រះគុណ និងសេចក្តីពិត... គ្មានអ្នកណាដែលឃើញព្រះឡើយ មានតែព្រះរាជបុត្រាតែមួយដែលគង់នៅក្នុងឱរាព្រះវរបិតាប៉ុណ្ណោះ ទ្រង់បានសំដែងឲ្យស្គាល់ព្រះអង្គ" ។ ពេលដែលថូម៉ាសមានការសង្ស័យអំពីការដែលព្រះយេស៊ូរស់ពីសុគតឡើងវិញ ព្រះយេស៊ូបានលេចឲ្យគាត់ឃើញ ហើយជំរុញគាត់ឲ្យដាក់ម្រាមដៃមកចំលើស្នាមដែកគោលដែលទ្រង់ត្រូវគេបោះភ្ជាប់នៅលើឈើឆ្កាងលើព្រះហស្តរបស់ព្រះអង្គ និងទៅលើចំណុចដែលគេបានចាក់ព្រះអង្គ ។ គឺទ្រង់យាងមកកៀកជិតនឹងយើងខ្លាំងណាស់ ។ តាមពិតទៅក្នុងកណ្ឌហេព្រើរនិយាយថា ព្រះរាជបុត្រានៃព្រះ "ហេតុនោះ បានជាគួរឲ្យទ្រង់ដូចជាបងប្អូនទ្រង់គ្រប់ជំពូកដែរ ដើម្បីឲ្យបានធ្វើជាសម្តេចសង្ឃដែលមានព្រះទ័យមេត្តាករុណា ហើយក៏ស្មោះត្រង់ក្នុងការទាំងប៉ុន្មានខាងឯព្រះប្រយោជន៍នឹងថ្វាយដង្វាយឲ្យធួននឹងបាបរបស់ប្រជាជនទាំងឡាយ" ដូច្នេះលទ្ធផល "ដ្បិតសម្តេចសង្ឃនៃយើង ទ្រង់មិនមែនមិនអាចនឹងអាណិតអាសូរដល់សេចក្តីកំសោយរបស់យើងរាល់គ្នានោះទេ ព្រោះទ្រង់បានត្រូវសេចក្តីល្បួងគ្រប់យ៉ាងដូចជាយើងរាល់គ្នាដែរ តែឥតធ្វើបាបឡើយ" ។ នៅឯបុណ្យណូអែលយើងប្រារព្ធពិធីបុណ្យខួបកំណើតអង្គដែលមាននាមថា អេម៉ាញូអែល ដែលមានន័យថា ព្រះគង់ជាមួយយើង ។ ព្រះដែលជាអាទិករដ៏អស្ចារ្យ និងមានគ្រប់ព្រះចេស្តាពិតប្រាកដណាស់បានយាងមកកៀកជិតនឹងយើងខ្លាំងណាស់ ។

ទាំងអស់នេះសុទ្ធតែជាដំណឹងល្អសំរាប់យើង ។ ទាំងអស់នេះគឺមានន័យដល់យើងថា យើងមិនត្រូវមានការភ័យខ្លាច ឬស្វែងរកជំនួយពីវិញ្ញាណ ឬអានុភាពណាផ្សេងៗទៀតឡើយ ទោះបីជាពិត ឬតាមការស្រមើស្រមៃក្តី ។ ព្រះដ៏អស្ចារ្យអង្គនេះផ្ទាល់យកព្រះទ័យទុកដាក់ចំពោះយើង ហើយទ្រង់មានអំណាចក្នុងការជួយសង្រ្គោះ ។ ព្រះយេស៊ូបានបង្រៀនថា ព្រះស្រឡាញ់មនុស្សខ្លាំងដល់ម៉្លេះ សូម្បីតែសក់មួយសរសៃដែលធ្លាក់ពីលើក្បាលយើងក៏ទ្រង់ជ្រាបដែរ ។ ទ្រង់បានប្រាប់ដល់សិស្សព្រះអង្គថា "ព្រះវរបិតា (ដែលជាព្រះ) ព្រះអង្គផ្ទាល់ស្រឡាញ់អ្នករាល់គ្នា ដោយព្រោះអ្នករាល់គ្នាបានស្រឡាញ់ខ្ញុំ ហើយ បានជឿថាខ្ញុំបានមកអំពីអំពីព្រះអង្គនោះឯង" ។ ដូច្នេះ "ព្រះវរបិតាខ្ញុំ នឹងប្រទានឲ្យអ្នករាល់គ្នាតាមអ្វីដែលអ្នករាល់គ្នាសូមដោយនូវឈ្មោះខ្ញុំ" ។ ព្រះយេស៊ូបាន សន្យាថា បើអស់អ្នកណាស្រឡាញ់ព្រះអង្គ ដោយធ្វើតាមសេចក្តីបង្រៀនរបស់ព្រះអង្គនោះ "ព្រះវរបិតារបស់ទ្រង់នឹងស្រឡាញ់ពួកគេ ហើយទ្រង់នឹងយាងទៅចំពោះពួកគេ ហើយនឹងសំណាក់នៅជាមួយពួកគេដែរ" ។ ចំណងដែលយើងមានចំពោះវិញ្ញាណទាំងអស់នោះនឹងត្រូវកាត់ផ្តាច់ ពីព្រោះតែព្រះដ៏ធំអស្ចារ្យស្រឡាញ់យើង ហើយគង់នៅជាមួយយើងដែលជាគ្រីស្តបរិស័ទ ហើយទ្រង់មានអំណាចលើសជាងវិញ្ញាណណាៗទាំងអស់ ។ បុណ្យណូអែលជាដំណឹងល្អ ព្រះដ៏ធំអស្ចារ្យបានយាងមកជៀកនឹងយើងហើយ ព្រមទាំងគង់ជាមួយអស់អ្នកណាដែលទទួលការអត់ទោសតាមរយៈព្រះរាជបុត្រារបស់ព្រះអង្គ ។

តើអ្នកបានទទួលសេចក្តីស្រឡាញ់របស់ព្រះតាមរយៈព្រះយេស៊ូហើយឬនៅ? តើអ្នកបាននិយាយថា "មួយជីវិតរបស់ខ្ញុំបំរើតែស្រមោល និងវិញ្ញាណដែលជារបស់ដែលខ្ញុំបានស្រមើស្រមៃ ប៉ុន្តែវាមិនពិតជានៅទីនោះឡើយ ឬជាវិញ្ញាណអាក្រក់ដែលខ្ញុំមិនគួរបំរើឡើយ ។ តែឥឡូវនេះ ខ្ញុំបានងាកចេញពីវាអស់ហើយ ដោយបែមករកព្រះដ៏ធំអស្ចារ្យដែលបានយាងមកជៀកនឹងខ្ញុំវិញ ដែលបង្ហាញខ្ញុំឲ្យឃើញតើទ្រង់ជាអង្គណានៅក្នុងអង្គព្រះយេស៊ូ?" តើអ្នកមានការ

យល់ដឹងច្បាស់ទេថា អ្វីទៅដែលជាគ្រីស្ទបរិស័ទ មិនមែនជាមនុស្សចាស់ដែលមានពុកមាត់ស ពាក់អាវពណ៌ក្រហម ដែលតែងតែឲ្យអំណោយនោះទេ ហើយក៏មិនមែនដើមណូអែល ដែលតែងតែតាក់តែងជាមួយភ្លើងចិញ្ចាចចិញ្ចែង និងចំរៀងពិសេសផ្សេងៗនោះដែរ ប៉ុន្តែគឺកំណើតរបស់មនុស្សម្នាក់ដែលជាព្រះ ហើយតាមអង្គនោះឯងដែលព្រះយាងមកកៀកជិតនឹងយើង ។

ដំណឹងបុណ្យណូអែល អំពីព្រះយាងមកកៀកនឹងយើងនៅក្នុងអង្គព្រះយេស៊ូ មិនមែនជាដំណឹងសំរាប់តែអស់អ្នកដែលមិនមែនជាគ្រីស្ទបរិស័ទនោះឡើយ ប៉ុន្តែដល់យើងដែលជាគ្រីស្ទបរិស័ទដែរ តើយើងដែលជាគ្រីស្ទបរិស័ទគិតយ៉ាងម៉េចដែរអំពីបុណ្យណូអែល តើយើងអបអរយ៉ាងដូចម្តេចដែរ?

យើងបានជួបគ្នាថ្ងៃនេះនៅក្នុងស្តាតដ៏ធំមួយ ជាមួយមនុស្សយ៉ាងច្រើនដែលបានចូលរួម ។ យើងមានបដា តន្ត្រី របាំ និងប្រព័ន្ធសំម្លេងយ៉ាងប្រណិតជាទីបំផុត ។ យើងបានអញ្ជើញភ្ញៀវកិត្តិយស និងភ្ញៀវពិសេសផ្សេងៗ ព្រមទាំងយើងទាំងអស់គ្នាស្លៀកពាក់សំលៀកបំពាក់យ៉ាងសមរម្យ ។ វាជាការល្អណាស់សំរាប់យើងក្នុងអបអរសាទរខួបកំណើតព្រះគ្រីស្ទក្នុងមធ្យោបាយនេះ ដោយបង្ហាញថា វាមានសារៈសំខាន់សំរាប់យើងខ្លាំងណាស់ ។ វាជាការល្អដែលយើងជួបជុំគ្នានៅក្នុងការជួបជុំយ៉ាងធំសំបើមនេះក្នុងនាមជាគ្រីស្ទបរិស័ទដែលមកពីក្រុមជំនុំ និងនិកាយផ្សេងៗ ដែលបង្ហាញឲ្យឃើញពីជំនឿរួមនៅក្នុងព្រះយេស៊ូ និងដោយសេចក្តីស្រឡាញ់របស់ទ្រង់ យើងអាចរួបរួមគ្នា ហើយការរួបរួមគ្នានេះឯងមានសារៈសំខាន់ជាងនិកាយខុសគ្នា ដែលពេលខ្លះបំបែកយើងចេញពីគ្នា ។ វាជាការល្អដែលយើងអាចថ្វាយបង្គំ និងរីករាយជាមួយគ្នាយ៉ាងដូច្នេះបាន ។

តើនេះគឺជាមធ្យោបាយតែមួយឬ ដែលយើងអាចអបអរបុណ្យណូអែលបាន? តើមានតែការប្រជុំជាធំឬ ដែលជាមធ្យោបាយតែមួយគត់

បង្ហាញឲ្យឃើញថា មានសារៈសំខាន់ចំពោះយើងដែលព្រះរាជបុត្រានៃព្រះបាន យាងមកនៅក្នុងចំណោមយើង ដើម្បីជាព្រះអង្គសង្គ្រោះនៃយើង?

សូមឲ្យយើងចងចាំថា បុណ្យណូអែល គឺជាការរំលឹកពីការយាងមករបស់អេម៉ាញូអែល "ព្រះគង់ជាមួយយើង" ។ សូមឲ្យយើងចងចាំដែរថា ព្រះយាងមកយើងតាមរយៈអង្គព្រះគ្រីស្ទ ទ្រង់បានយាងមកកៀកជិតនឹងយើង មិនមែនដូចជាប្រធានាធិបតី មហាក្សត្រ ឬនាយករដ្ឋមន្ត្រី ដូចសព្វថ្ងៃ នេះឡើយ ដែលហ៊ុំព័ទ្ធដោយអ្នកការពារ ដើម្បីរក្សាមនុស្សសាមញ្ញឲ្យនៅឆ្ងាយ ហើយអស់លោកទាំងនោះមានសំលៀកបំពាក់យ៉ាងថ្លៃៗ ។ ទ្រង់បានយាងមកកៀក មកប្រសូត្រជាមួយគ្រួសារដែលគ្មានទីជំរក រុំដោយក្រណាត់រហែក ហើយផ្ទំនៅក្នុងស្នូកដែលសំរាប់ដាក់ចំណីសត្វ ។ អ្នកមកសួរព្រះអង្គដំបូងគឺជាអ្នកគង្វាលចៀម ។ ទ្រង់មើលទៅហាក់បីដូចជាមនុស្សសាមញ្ញបំផុត ហើយចំរើនវ័យឡើងនៅក្នុងភូមិតូចមួយដែលមនុស្សជាច្រើនមិនអាច ជឿបានថាទ្រង់មានអ្វីពិសេសនោះឡើយ ។ លោកយ៉ូហាននិយាយថា ទ្រង់យាងមកកៀកខ្លាំងណាស់ រហូតដល់ភ្នែកគាត់បានឃើញនិងដៃគាត់បានប៉ះព្រះអង្គ ។ គ្រីស្ទបរិស័ទមិនមែនស្ថិតនៅការប្រជុំធំៗ និងកម្មវិធីថ្លៃៗនោះទេ ទោះបីខ្ញុំបាននិយាយរួចមកហើយថា វាជាល្អ និងមានកន្លែងវាក៏ដោយ ។ ប៉ុន្តែបុណ្យណូអែល គឺជាការដែលទ្រង់យាងមកកៀកជិតនឹងមនុស្សសាមញ្ញរាល់ថ្ងៃ និងការរស់នៅរាល់ថ្ងៃក្នុងជីវិតគេម្នាក់ៗ ។

ដូច្នេះក្នុងនាមយើងជាគ្រីស្ទបរិស័ទ ប្រសិនបើចង់ឲ្យអ្នកជិតខាងយើងដែលមិនមែនជាគ្រីស្ទបរិស័ទ ស្គាល់ព្រះគ្រីស្ទដែលយើងស្រឡាញ់នេះ យើងត្រូវតែជា "អេម៉ាញូអែល" តូចដល់ពួកគេ ។ ព្រះយេស៊ូមានបន្ទូលដល់សិស្សរបស់ព្រះអង្គថា "ដូចជាព្រះវរបិតាបញ្ជូនខ្ញុំ ខ្ញុំក៏បញ្ជូនអ្នករាល់គ្នាឲ្យទៅដែរ" ។ ទ្រង់បញ្ជូនយើង ដូចជាព្រះវរបិតាបញ្ជូនទ្រង់អីចឹងដែរ ដើម្បីទៅរស់នៅក្នុងចំណោមមនុស្ស ហើយបង្ហាញពួកគេអំពីជីវិតរបស់យើងឲ្យស្គាល់

ព្រះអង្គ ថាមានលក្ខណៈយ៉ាងដូចម្តេច ។ ដើម្បីឲ្យយើងអាចយកចិត្តទុកដាក់ចំពោះពួកគេបាន គឺតាមរយៈសេចក្តីត្រូវការ និងបញ្ហាប្រចាំថ្ងៃរបស់ពួកគេ ។

ដូច្នេះនៅពេលដែលគ្រីស្ទបរិស័ទម្នាក់ យកអាហារទៅឲ្យម្តាយដ៏ក្មេងម្នាក់កំពុងរង់ចាំសេចក្តីស្លាប់ដោយជម្ងឺអេដស៍ នោះហើយគឺជាបុណ្យណូអែលសំរាប់ស្ត្រីនោះ ។ គឺមានម្នាក់ដែលចូលទៅកៀកនឹងភាពក្រីក្ររបស់គាត់ និងចែកចាយដល់នាងនូវព្រះនាមនៃព្រះ ។ នៅពេលដែលក្រុមជំនុំជួបជុំគ្នា ហើយសំរេចចិត្តលាងសំអាតផ្លូវរបស់អ្នកជិតខាងខ្លួន ឬបង្រៀនក្មេងៗអនាថាក្នុងស្រុកនៅតាមផ្លូវឲ្យចេះអានអក្សរ ឬផ្តល់អំណោយជាអង្ករដល់គ្រួសារដែលខូចផលស្រូវតាមរយៈទឹកជំនន់នោះហើយ ជាអត្ថន័យនៃបុណ្យណូអែលនោះ ។ ព្រះបានយាងមកកៀកនឹងយើងហើយ ទោះជាយើង នៅកន្លែងណាក៏ដោយ យើងអាចឃើញថា ទ្រង់ជានរណា ហើយទទួលនូវបទពិសោធន៍នៃសេចក្តីស្រឡាញ់ និងការយកព្រះទ័យទុកដាក់របស់ព្រះអង្គ ។ ការដែលយើងអបអរសាទររបៀបនេះ ផ្តល់ឲ្យយើងនូវការលើកទឹកចិត្តយ៉ាងខ្លាំង ហើយលើកតំកើងព្រះទៀតផង ។ ប៉ុន្តែ បើមិនយ៉ាងដូច្នេះទេ អ្នកជិតខាងរបស់យើងដែលមិនមែនជាគ្រីស្ទបរិស័ទគេនឹងនិយាយថា "គ្រីស្ទបរិស័ទគេប្រារព្ធពិធីបុណ្យសាសនារបស់ពួកគេម្តងទៀតហើយ" ។ ការដែលពួកគេធ្វើនោះ មិនទាក់ទងអ្វីនឹងខ្ញុំទេ ខ្ញុំក៏មានសាសនា និងពិធីបុណ្យផ្ទាល់របស់ខ្ញុំដែរ" ។ ផ្ទុយទៅវិញ ប្រសិនបើយើងបំរើកៀកនឹងគេ នៅកន្លែងរបស់គេក្នុងផ្លូវពិត និងមានអត្ថន័យនោះ គេនឹងមានការយល់ដឹងថា បុណ្យណូអែល គឺជាការយាងមករបស់អេម៉ាញូអែល "ព្រះគង់ជាមួយយើង" នៅចំកន្លែងដែលយើងរស់នៅធ្វើការលេង និងបញ្ហា ។ ប្រហែលជាពេលមួយ ពួកគេនឹងមានអារម្មណ៍លើកទឹកចិត្តដោយលះបង់ការភ័យខ្លាចនៃវិញ្ញាណតូចៗដែលពួកគេមាន ដោយព្រោះតែពួកគេទទួលស្គាល់ថា ព្រះដ៏ធំអស្ចារ្យបានយាងមកដោយផ្ទាល់កៀកជិតនឹងគេហើយ ។